
រឿង
ផ្លែប៉ែនណំលេងពួន

# រឿង ផ្លែប៉ែនធំលេងពួន

និពន្ធដោយ លោក ឆាយ ផល្លី
គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្មគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១០



នៅចំការក្រោយផ្ទះនារី មានដើមប៉ែនមួយដែល

មានផ្លែមួយធំប្លែកពីគេ ។



ថ្ងៃមួយ ផ្លែប៉ែនធំចង់លេងពួន ព្រោះវាឃើញ

កុមារជាច្រើនកំពុងរត់លេងពួនយ៉ាងសប្បាយ ។





មានពេលមួយនោះ នារីបាន
លេងក្រោមដើមប៉ែន តែម្នាក់ឯង ។



ឃើញដូច្នោះ ផ្លែប៉ែនធំក៏និយាយថា

"សួស្តី បងនារី! ខ្ញុំចង់លេងពួនជាមួយបង!" ។



**នារី** "តើប្អូនចុះមកយ៉ាងដូចម្ដេច?" ។

**ផ្លែប៉ែនធំ** "សូមបងដាក់ជណ្ដើរមក ទើបខ្ញុំអាចចុះបាន" ។

នារីក៏ទៅយកជណ្ដើរ មកដាក់ឱ្យផ្លែប៉ែនធំនោះចុះ ។





ដោយភ្លាត់ស្មៀត ផ្លែប៉ែនធំក៏របូតដៃ ហើយធ្លាក់

មកដី ព្លក្កុក..! ។

អូយ..! ផ្លែប៉ែនបានធ្លាក់មកលើគំនរ

ស្លឹកឈើងាប់ៗ នៅក្បែរគល់ដើមប៉ែន ។

នារីខំសម្លឹងរកផ្លែប៉ែនធំ ហើយស្រែក "អើ! ប្អូនប៉ែន..!" ។

"ក៊ូក..! ខ្ញុំនៅខាងត្បូងបង ចម្ងាយមួយជំហាន" ។



នារីក៏ចាប់ផ្ដើមរាប់ មួយ..! ហើយឈានមួយជំហានទៅទិស
ខាងត្បូង ។ ពេលនោះ ផ្លែប៉ែនធំបានរត់គេចទៅទិសខាងជើងវិញ ។



នារីខំសម្លឹងរកផ្លែប៉ែនធំ ហើយស្រែក "អើ! ប្អូនប៉ែន..!" ។

"ក៊ូក..! ខ្ញុំនៅខាងជើងបង ចម្ងាយពីរជំហាន" ។



នារីក៏ចាប់ផ្ដើមរាប់ មួយ ពីរ..! ហើយឈានពីរជំហានទៅទិស
ខាងជើង ។ ឯផ្លែប៉ែនធំរត់គេចទៅទិសខាងលិច ។



នារីខំសម្លឹងរកផ្លែប៉ែនធំ ហើយស្រែក "អើ! ប្អូនប៉ែន..!" ។

"កុ៎ក..! ខ្ញុំនៅខាងលិចបង ចម្ងាយបីជំហាន" ។



នារីក៏ចាប់ផ្តើមរាប់ មួយ ពីរ បី..! ហើយឈានបីជំហានទៅទិសខាងលិច ។ ផ្លែប៉ែនធំក៏រត់គេចទៅទិសខាងកើត ។



នារីខំសម្លឹងរកផ្លែប៉ែនធំ ហើយស្រែក "អើ! ប្អូនប៉ែន..!" ។

"ក៊ូក..! ខ្ញុំនៅខាងកើតបង ចម្ងាយបួនជំហាន" ។



នារីក៏ចាប់ផ្ដើមរាប់ មួយ ពីរ បី បួន..! ហើយឈានបួន

ជំហានទៅទិសខាងកើត ។



អ៊ឹះ..! រកមិនឃើញទេ..!



នារីស្រែកសួរ "ប្អូនប៉ែនពួននៅឯទីណាហ្នឹង?" ។

គ្មានចម្លើយ..!





នារីក៏ត្រឡប់មកកាន់ដើមប៉ែនវិញ ។



នារីឈរផ្អែកនឹងគល់ប៉ែន ។ ភ្លាមនោះ ជើងរបស់នាងប៉ះនឹងដុំមូលមួយទន់ហើយត្រជាក់ៗ មានក្លិនក្រអូបភាយៗ ។

ស្រាប់តែឮសំឡេងផ្លែប៉ែនធំស្រែក "ដល់ទីហើយ..!" ។

...... ចប់ ......






អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association
*Move forward, hand in hand.*